# សេចក្តីផ្តើម និងទិដ្ឋភាពទូទៅនៃការការពារអ្នកប្រើប្រាស់នៅកម្ពុជា

ដោយ គង់ ផល្លា & ឡុង ច័ន្ទបូរមី

ការការពារអ្នកប្រើប្រាស់សំដៅទៅលើវិធានការគាំពារ និងលើកកម្ពស់សុខុមាលភាព និងផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់។ វិធានការគាំពារអ្នកប្រើប្រាស់ដូចជាការអប់រំសម្រាប់អ្នកប្រើប្រាស់ ការចល័ត និងតំណាងភាព ធ្វើការធានាឲ្យបានថាអ្នកប្រើប្រាស់អាចទទួលព័ត៌មានគ្រប់គ្រាន់ដើម្បីសម្រេចចិត្តទៅលើជម្រើសរបស់ពួកគាត់ ហើយអ្នកផលិត និងអ្នកលក់នឹងបំពេញទៅតាមការសន្យាចំពោះផលិតផលនិងសេវាកម្មដែលពួកគេផ្តល់ជូន។ របបនៃការការពារអ្នកប្រើប្រាស់នៅប្រទេសកម្ពុជាមានអាយុកាលក្មេងជាងគេនៅតំបន់អាស៊ានក៏ព្រោះតែច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ទើបតែបានអនុម័តក្នុងខែ វិច្ឆិកា ឆ្នាំ២០១៩នេះទេ។ សេចក្តីបង្គាប់ដ៏សំខាន់សម្រាប់ការអនុវត្តច្បាប់នេះជាទំនួលខុសត្រូវរបស់នាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំដែលស្ថិតក្រោមក្រសួងពាណិជ្ជកម្ម។ បច្ចុប្បន្ន អនុក្រិត្យ និងសេចក្តីប្រកាសពាក់ព័ន្ធនានាកំពុងតែត្រូវបានព្រាងក្នុងចំណោមអនុក្រិត្យផ្សេងទៀតទាក់ទិននឹងរដ្ឋធម្មនុញ្ញ និងសមសភាពគណកម្មការអន្តរក្រសួង។

ក្រៅពីច្បាប់ការពារអ្នកប្រើប្រាស់នៅឆ្នាំ ២០១៩ មានច្បាប់ និងបទប្បញ្ញត្តិមួយចំនួនទៀតដែលពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ដែលមានដូចជា ច្បាប់ស្តីពីវិធានការទប់ស្កាត់ការរីករាលដាលនៃមេរោគកូវីត-១៩ និងជំងឺឆ្លងផ្សេងៗទៀត(២០២១) ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច(២០១៩) ច្បាប់ស្តីពីការសាងសង់ (២០១៩) ច្បាប់ស្តីពីការគ្រប់គ្រងវិជ្ជាជីវៈសុខាភិបាល (២០១៦) ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម(២០១៦) ច្បាប់ស្តីពីទូរគមនាគមន៍ (២០១៥) ច្បាប់ស្តីពីសមាគមន៍ និងអង្គការក្រៅរដ្ឋាភិបាល(២០១៥) ច្បាប់ស្តីពីមាត្រវិទ្យា(២០០៩) ច្បាប់ស្តីពីការធានារ៉ាប់រង(២០១៤) ច្បាប់រដ្ឋប្បវេណី (២០០៧) ច្បាប់ស្តីពីស្តង់ដារ (២០០៧) សេចក្តីប្រកាសស្តីអំពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន (២០០៦) ច្បាប់ស្តីពីប្រៃសណីយ៍(២០០២) ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថិភាពនៃផលិតផល(២០០០) ច្បាប់ស្តីពីការគ្រប់គ្រងវេជ្ជសាស្ត្រឯកជន វេជ្ជបណ្ឌិត និងជំនួយវេជ្ជសាស្ត្រ (២០០០) ច្បាប់ស្តីពីអគ្គិសនី(២០០០) ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ(១៩៩៩) ច្បាប់ស្តីពីការគ្រប់គ្រងឱសថ (១៩៩៦) ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី (១៩៩៥) និងបទប្បបញ្ញត្តិរងដទៃទៀតដែលតម្រូវឲ្យមានក្នុងច្បាប់ខាងលើនេះត្រូវបានបង្កើតឡើងដោយក្រសួង និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗ។

ការបោះពុម្ពផ្សាយរបស់កិច្ចពិភាក្សាស្តីអំពីច្បាប់ក្រោមចំណងជើង «ច្បាប់ក្នុងសម័យកាលឌីជីថលៈ កិច្ចការពារអ្នកប្រើប្រាស់» មានផ្ទុកនូវអត្ថបទសិក្សាដាក់ជូនដោយអ្នកស្រាវជ្រាវកម្ពុជាវ័យក្មេង និងបញ្ញវន្តផ្នែកច្បាប់ដែលបានផ្តល់នូវទស្សនៈវិភាគនៅក្នុងអត្ថបទរបស់គាត់រៀងៗខ្លួន។ ក្នុងនោះរួមមានធាតុសំខាន់ៗមួយចំនួននៃក្របខណ្ឌច្បាប់សម្រាប់ការពារអ្នកប្រើប្រាស់។ អត្ថបទនីមួយៗសុទ្ធតែមានបង្កប់នូវគំនិតសំខាន់ពញ្ញាក់ការគិតដើម្បីជាគ្រឹះសម្រាប់អ្នកបង្កើតគោលនយោបាយយកទៅពិចារណាដើម្បីលុបបំពេញចន្លោះខ្វះខាតនៅក្នុងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលមានស្រាប់ និងសម្រាប់សិស្សានុសិស្ស អ្នកស្រាវជ្រាវទទួលបានការយល់ដឹងស៊ីជម្រៅទៅលើវិស័យដែលទើបតែលេចចេញនៅក្នុងរង្វង់ប្រព័ន្ធច្បាប់ និងប្រព័ន្ធអប់រំនៃប្រទេសកម្ពុជា។ អត្ថបទសិក្សា

ទាំងនេះត្រូវបានដាក់បញ្ចូលជាមួយគ្នាពីជំពូកទី១ ដល់ជំពូកទី៧ ដោយមានសេចក្តីសង្ខេបដូចតទៅ៖

### ជំពូកទី១៖ ការយល់ឃើញរបស់អ្នកប្រើប្រាស់ទៅលើសិទ្ធិរបស់អ្នកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា

ជំពូកនេះពន្យល់អំពីទស្សនៈ ឬការយល់ឃើញអំពីការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈមទាក់ទងនឹងសិទ្ធិអ្នកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាក្នុងការប្រើសិទ្ធិរបស់ពួកគាត់។ ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដូចជាការសិក្សាទៅលើព័ត៌មានដែលមានស្រាប់ ការស្រង់មតិផ្អែកលើកម្រងសំណួរ និងបទសម្ភាសន៍ជាមួយនឹងអ្នកប្រើប្រាស់ដែលភាគច្រើនជាសិស្សមហាវិទ្យាល័យ។

### ជំពូកទី២៖ វប្បធម៌ និងច្បាប់របស់ប្រទេសកម្ពុជាស្តីពីការការពារឯកជនភាព និងទិន្នន័យ និងពេលអនាគត

ជំពូកទី២ ធ្វើការពិនិត្យទៅលើវប្បធម៌កម្ពុជា និងច្បាប់ស្តីអំពីការការពារទិន្នន័យ និងឯកជនភាព ក៏ដូចជាឥទ្ធិពលរបស់វាទៅលើអនាគតនៃការអភិវឌ្ឍរបស់កម្ពុជា។ ក្រោមការពិនិត្យពិច័យខ្ពស់ អត្ថបទនេះនឹងធ្វើការដកស្រង់មធ្យោបាយនានារបស់សហរដ្ឋអាមេរិច និងសហគមន៍អឺរ៉ុបក្នុងការការពារទិន្នន័យ និងឯកជនភាព ព្រមទាំងវប្បធម៌ សាវតា និងនយោបាយរបស់ប្រទេសទាំងនោះ។ អត្ថបទនេះមិនមែនជាការវិភាគគ្រប់ជ្រុងជ្រោយទៅលើសាវតានៃឯកជនភាពនៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែជាចំណុចចាប់ផ្តើមនៃការពិនិត្យឲ្យបានស៊ីជម្រៅបន្ថែម។

### ជំពូកទី៣៖ ការការពារទិន្នន័យ និងឯកជនភាពនៅក្នុងសម័យកាលឌីជីថលដែលស្តីអំពីមធ្យោបាយបែបសន្និនិយមក្នុងការការពារទិន្នន័យ និងឯកជនភាពនៅក្នុងប្រទេសកម្ពុជា

ជំពូកនេះធ្វើការពិនិត្យឡើងវិញទៅលើនិតិវិធីដែលមានស្រាប់ស្តីអំពីការការពារទិន្នន័យដែលបានយកពីច្បាប់ទូទៅ និងច្បាប់ទៅតាមវិស័យនីមួយៗ បន្ទាប់មកធ្វើការបែងចែកនីតិវិធីទាំងនោះជា៤ ថ្នាក់រួមមាន សិទ្ធិទទួលបានភាពឯកជន សិទ្ធិបុគ្គលិកលក្ខណៈ សិទ្ធិរក្សាការសម្ងាត់ក្នុងវិជ្ជាជីវៈ និងសិទ្ធិទទួលបានសុវត្ថិភាពផ្នែកទិន្នន័យ។ អត្ថបទស្រាវជ្រាវនេះមានគោលបំណងចង់ឲ្យមានការវិភាគ និងការពិភាក្សាដោយផ្អែកលើទ្រឹស្តីទៅលើនីតិវិធី និងសង្កត់ទៅលើបញ្ហាប្រឈមខាងគោលលិទ្ធិនៅពេលដែលយកមកអនុវត្តនៅក្នុងក្របខណ្ឌច្បាប់របស់ប្រទេសកម្ពុជា ព្រមទាំងស្នើឲ្យមានការពារទិន្នន័យក្រោមសិទ្ធិបុគ្គលិកលក្ខណៈដែលសិទ្ធិឯកជនភាពស្ថិតនៅក្នុងសំណុំរងនៃសិទ្ធិបុគ្គលិកលក្ខណៈ ហើយរាល់ដំណោះស្រាយតាមអង្គនីតិបញ្ញត្តិណាមួយទាក់ទងនឹងការពារទិន្នន័យគប្បីផ្អែកទៅលើគោលការណ៍នេះដើម្បីឲ្យវាមានភាពថិតថេរមិនផ្លាស់ប្តូរទូទាំងឋានានុក្រមច្បាប់ទាំងមូលរួមមានរដ្ឋធម្មនុញ្ញ និងច្បាប់រដ្ឋប្បវេណី។ ជាទីបញ្ចប់ អត្ថបទស្រាវជ្រាវនេះក៏រុករកមធ្យោបាយដែលមានសក្តានុពលដើម្បីបង្កើតឲ្យមាននីតិវិធីរួមមួយសម្រាប់ទិន្នន័យផ្ទាល់ខ្លួននៅប្រទេសកម្ពុជា។

### ជំពូកទី៤៖ ការលក់ដូរទំនិញតាមប្រព័ន្ធអនឡាញ និងទំនួលខុសត្រូវទាំងផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌដើម្បីរឹតបន្តឹងការការពារអ្នកប្រើប្រាស់

ជំពូកនេះមានបំណងស្វែងរកទំនួលខុសត្រូវទាំងពីរប្រភេទដែលអាចអនុវត្តចំពោះបទល្មើសនានានៃការលក់ដូរតាមប្រព័ន្ធអនឡាញ។ ដើម្បីធ្វើដូចនេះបាន មូលដ្ឋានច្បាប់ និងប្រភេទនៃការទទួលខុសត្រូវ រួមទាំងអន្តរកម្មរបស់វាជាមួយនឹងច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗនៅក្នុងប្រទេសកម្ពុជានឹងត្រូវយកមកពិភាក្សា។ ទស្សនាទាននៃការថ្លែងមិនពិត និងផលិតផលខូចគុណភាពក៏នឹងត្រូវយកមកបង្ហាញដែរ។ ទ្រឹស្តីច្បាប់ នីតិសាស្ត្រ និងច្បាប់របស់យុត្តាធិការផ្សេងទៀតនឹងត្រូវយកមកប្រើប្រាស់ជាឯកសារយោង។

**ជំពូកទី៥៖ ការបញ្ចេញព័ត៌មានមុនកិច្ចសន្យាសម្រាប់អ្នកប្រើប្រាស់ ហើយតើកម្ពុជាអាចរៀនសូត្រពីសហគមន៍អឺរ៉ុបបានយ៉ាងដូចម្ដេច?**

ទីមួយ ជំពូកនេះណែនាំអំពីសារៈសំខាន់នៃការបញ្ចេញព័ត៌មានឲ្យទៅអ្នកប្រើប្រាស់។ ទីពីរ ការស្រាវជ្រាវនេះផ្តល់នូវក្របខណ្ឌសម្រាប់វិភាគទៅលើការបញ្ចេញព័ត៌មានមុនកិច្ចសន្យាពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចនៅក្នុងសហគមន៍អឺរ៉ុប និងកម្ពុជា។ ដោយសារតែយើងយកសហគមន៍អឺរ៉ុបមកធ្វើជាចំណុចគោលសម្រាប់ប្រៀបធៀប យើងនឹងពិនិត្យលើបញ្ហាប្រឈមនានាដែលសហគមន៍អឺរ៉ុបអាចជួបប្រទះ និងយុទ្ធសាស្ត្រក្នុងការយកឈ្នះបញ្ហាទាំងនោះ។ ជាចុងក្រោយ អត្ថបទនេះក៏ផ្តល់អនុសាសន៍ណែនាំឲ្យកម្ពុជាជ្រើសយករបៀបនៃការអនុវត្តល្អបំផុតរបស់សហគមន៍ដែលកម្ពុជាអាចយកមកប្រើប្រាស់បាននៅក្នុងរង្វង់ក្របខណ្ឌបទប្បញ្ញត្តិរបស់ខ្លួន។ ដោយសារតែកម្ពុជាកំពុងតែឆ្លងកាត់ការផ្លាស់ប្តូរមួយដែលឆ្ពោះទៅរកទីផ្សារឌីជីថល លទ្ធផលនៃការសិក្សានៅក្នុងអត្ថបទនេះមានបំណងចង្អុលបង្ហាញ និងលើកកម្ពស់វិធានការទាំងឡាយណាដែលប្រកបដោយប្រសិទ្ធផលដើម្បីពង្រឹងការការពារអ្នកប្រើប្រាស់នៅក្នុងវិស័យពាណិជ្ជកម្មអេឡិត្រូនិចនៅប្រទេសកម្ពុជា។

**ជំពូកទី៦៖ សេចក្តីអនុម័តស្តីពីសិទ្ធិក្នុងការដកខ្លួនដើម្បីជាយន្តការក្នុងការពារអ្នកប្រើប្រាស់នៅក្នុងវិស័យពាណិជ្ជកម្មអេឡិចត្រូនិច និងមេរៀនដែលបានរៀនពីក្របខណ្ឌច្បាប់របស់សហគមន៍អឺរ៉ុប**

អត្ថបទនេះមានគោលបំណងលើកចំណុចខ្វះខាតដែលមាននៅក្នុងច្បាប់ប្រទេសកម្ពុជាដើម្បីរកដំណោះស្រាយតាមរយៈការប្រៀបធៀបជាមួយនឹងក្របខណ្ឌនៃសិទ្ធិក្នុងការដកខ្លួនរបស់សហគមន៍អឺរ៉ុប និងធ្វើការណែនាំឲ្យមានការអនុម័តសិទ្ធិក្នុងការដកខ្លួនដើម្បីជាយន្តការពង្រឹងការការពារអ្នកប្រើប្រាស់នៅក្នុង
វិស័យពាណិជ្ជកម្មអេឡិចត្រូនិចក្នុងប្រទេសកម្ពុជា។

**ជំពូកទី៧៖ ដំណើរឆ្ពោះទៅរកសកម្មភាព និងភាពសកម្មរបស់អ្នកប្រើប្រាស់ដែលរួមមានការពិចារណាផ្នែកច្បាប់ និងក្នុងបរិបទជាក់ស្តែងក្នុងការបង្កើតសមាគមអ្នកប្រើប្រាស់នៅកម្ពុជា**

ជំពូកចុងក្រោយព្យាយាមធ្វើនិទស្សន៍អំពីសេចក្តីត្រិះរិះផ្នែកច្បាប់ និងក្នុងបរិបទជាក់ស្តែង និងធ្វើការសញ្ជឹងគិតទៅលើខ្លឹមសារនៃការបង្កើតសមាគមអ្នកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដោយពិនិត្យទៅលើក្របខណ្ឌច្បាប់ បទពិសោធន៍ពីប្រទេសដទៃ ព្រមទាំងក្របខណ្ឌច្បាប់ប្រទេសកម្ពុជាពាក់ព័ន្ធនឹងការកកើតនៃសមាគមអ្នកប្រើប្រាស់។